## ភាគទី ៥

# ឥន្ទ្របថនគរ រាជអាណាចក្រថ្មី

តមក បាណ្ឌពក្សត្រិយ៍ទាំង ៥ អង្គ បាននាំគ្នាទៅសាងរាជធានីទីក្រុងថ្មីនៅខាណ្ឌវបថ ចាប់ផ្ដើមកសាងកាប់គាស់ឈើព្រៃចូកចាំងជម្រះដីទីទួលឲ្យរាបស្មើផ្ទៃស្រេចហើយ ទើបសាងព្រះរាជមន្ទីរ ព្រមកំពែងដ៏វិចិត្ររចនា ហាក់ដូចទេពនិម្មិត តាំងនៅឆ្នេរទន្លេយមុនាខ្ពស់ត្រដឹមស្ពឹមស្កៃលេចកំពូលច្រូង សាងប្រាង្គណ៍លលៃគ្របទៅលើទន្លេ ជីកស្រះ, ជីកគូ និងប្រឡាយជ្រលងជងអូរ សម្រាប់បង្ហូរទឹកចេញចូលតាមត្រូវការ ។ ធ្វើទាំងឧទ្យានសួនផ្កា និងសួនផលានុផលជុំវិញព្រះរាជមន្ទីរ សុទ្ធសឹងតែព្រឹក្សាលតាជាតិដ៏មានផ្លែផ្កា គួរជាទីទស្សនានៃអ្នកដែលបានទៅដល់យល់ឃើញ .មានជ្រលងទឹកដ៏ថ្លាហូរអំពីទន្លេយមុនាចូលទៅក្នុងឧទ្យាន ដាក់នៅក្នុងរអាងដែលមានក្នុងសួនជាអន្លើ ៗ សម្រាប់ចិញ្ចឹមឈើព្រៃព្រឹក្សាលតជាតិ ឲ្យស្រស់ខ្ចីជានិច្ច, មានហ្វូងរមាំង ប្រើស ទ្រាយ ទន្សាយ ក្ដាន់ ដើររកស៊ីក្នុងតិណទ្យានដ៏ខៀវខ្ចី វិស័យដូចជាព្រៃវិចិត្ររចនា, មានហ្វូងបក្សីនជាតិហិចហើរឆ្វៀលឆ្វាត់ ចាប់មែកព្រឹក្សាមយូរាដើរកៃក្រាយក្បែរគុម្ពឈើខ្លះទំលើមែកឈើត្រសាសស្លាប ក្ងោក ប៉ោលតោក នូវសេក ចាបយាសយំកេបកាបតាមភាសាសកុណា ឆ្លាសឆ្លើយរងំព្រៃ ត្រូវនឹង

សម្លេងវៃយំងាង ។ ឮហើយភ័ន្តភាំង ឈានឈប់ឈរស្តាប់ស័ព្ទបក្សី ។

អាស្រ័យលោកសង្ខារតាក់តែងឡើងតាមធម្មតាខ្លះ អាស្រ័យវិទ្យាសាស្ត្ររបស់មនុស្សរចនាឡើងខ្លះ ឆោមលំអនៃធម្មជាតិទាំងឡាយនោះ ទើបប្រមូលមកមានព្រមនៅទីនោះ ជាទីសម្រាន្តរម្យរីករាយនៃអ្នកដ៏ជាម្ចាស់ ។ លុះកសាងវាំងរួចស្រេចហើយ បាណ្ឌពក្សត្រិយ៍ឡើងគង់វាំងថ្មី តាមវិធីបុរាណសន្មតនាមថា «ឥន្ទ្របថ» ព្រោះល្អប្រហែលរម្យស្ថានក្នុងត្រៃត្រឹង្សភពរបស់សម្តេចអមរេន្ទ្រាធិរាជ ។

គ្រានោះ អ្នកនគរព្រមព្រៀងគ្នាអញ្ជើញយុធិស្ឋិរឡើងសោយរាជ្យសម្បត្តិនាក្រុងឥន្ទ្របថ ដោយអំណាចម្លប់ព្រះពោធិសម្ភាររបស់ព្រះអង្គ ប្រទេសក៏ស្តុកស្តម្ភសម្បូរឡើងគ្រប់យ៉ាង ប្រជារាស្ត្រនៅជាសុខក្សេមក្សាន្តសព្វទិវារាត្រី ឥតមានភិតភ័យដោយរឿងរ៉ាវអ្វីឡើយ ទ្រង់ផ្សាយព្រះរាជានុភាព វាតវង់ចេញទៅបន្តិចម្តង ។ ជារឿយ ។ ទៅ ទាល់តែឥន្ទ្របថរដ្ឋរីកធំទូលំទូលាយជាកម្រិតដើម ។ មិនមែនគ្រាន់តែមានដែនដីធំប៉ុណ្ណោះទេ នៅមានកងកម្លាំងរេហ៍ពលសាកលយោធាដ៏ក្លាហានជាអនេកអនន្តទៀត, ទ្រង់នូវឫទ្ធិអំណាចឥស្សរភាពក្នុងផ្លូវរដ្ឋប្រសាសនោបាយយ៉ាងស្រួលឆ្នើម ។ លុះព្រះបាទយុធិស្ឋិរ ទ្រង់ជ្រាបថា ការព្រះនគរបានចម្រើនរុងរឿងធំទូលាយដល់



ខ្នាតហើយ ការគ្រប់គ្រងក៏ខ្ជាប់ខ្ជួនបរិបូណ៌គ្រប់យ៉ាងហើយ ទ្រង់នូវព្រះតេជានុភាព និងព្រះកិត្តិយសជា «ព្រះមហារាជា» ទ្រង់ប្រាថ្នានឹងធ្វើ «ពិធីស្វយជនកម្ម គឺការបូជាមហារាជ» ដើម្បីប្រកាសឥស្សរភាពរបស់ទ្រង់ជាមហារាជា ឲ្យផ្សាយទូទៅក្នុងពពួកក្សត្រិយ៍ដែលគ្រងនគរតូចតាចនៅជិតខាងព្រះរាជរដ្ឋសីមា ទើបទ្រង់ត្រាស់បញ្ជាព្រះអនុជទាំង ៤ អង្គ ឲ្យយាត្រាទៅកាន់ដែនប្រទេសរាជជិតខាងទាំងនោះ ដើម្បីប្រកាសឥស្សរភាពជាក្សត្រិយ៍ធំលើនានាប្រទេសរាជ ។ ពួកប្រទេសរាជដែលព្រមចុះចូលក៏បានទទួលការអញ្ជើញមកប្រជុំក្នុងពិធីស្វយជនកម្ម ។ ចំណែកប្រទេសដែលរឹងទទឹង ឬតស៊ូក៏ត្រូវប្រហារឲ្យខ្ទេចខ្ទីអស់ទៅ ដែនដីត្រូវរឹបយកមករួមចូលជាអាណាចក្ររបស់ព្រះមហារាជាឥន្ទ្របថ ។

រាជស្វយពិធីគ្រានេះ បានសម្រេចផលជាយ៉ាងធំក្នុងផ្លូវរដ្ឋប្រសាសនោបាយ ធ្វើឲ្យព្រះបាទយុធិស្ឋិរតាំងនៅមាំមួនក្នុងរាជសម្បត្តិបានផ្សាយព្រះរាជអាណា គ្របទៅលើសាមន្តរាជតូចធំទាំងឡាយ ជាបច្ច័យឲ្យព្រះអង្គមានមិត្រមេត្រីនឹងមហារាជាក្នុងប្រទេសឥណ្ឌៀភាគខាងលើជាច្រើនអង្គ ហើយជួយបញ្ជូនព្រះតេជានុភាពនិងកិត្តិប្រវត្តិឲ្យខ្ចរខ្ចាយសាយភាយទូទៅរាល់ប្រទេស ។

លុះស្រេចការពិធីនេះហើយ មិនយូរប៉ុន្មានទុរយោធន៍ ព្រមទាំងរាជបរិពារ និងព្រះសកុនិជាបិតុលាធិរាជនៃគណៈក្សត្រិយ៍

គោរពទៅប្រញាតឯនគរឥន្ទ្របថ, បានជាឧស្សាហ៍ ស្តេចទៅទាំងម្ល៉ឹង ព្រោះព្រះហឫទ័យពោរពេញទៅដោយសេចក្តីឫស្យា ជាងការទៅសម្តែងសេចក្តីត្រេកអរក្នុងរឿងសាងរាជធានីថ្មី ។ សារពើវត្ថុដែលទ្រង់បានទតឃើញ, សារពើសូរស័ព្ទដែលទ្រង់បានស្តាប់, សារពើអារម្មណ៍ដែលទ្រង់បានប្រារព្ធនឹកដល់ សុទ្ធតែជាគ្រឿងជម្រុញឲ្យកើតសេចក្តីឫស្យា និងអាឃាតកាន់តែខ្លាំងឡើង ។ នឹងគន់មើលទៅភូមិប្រទេសឥន្ទ្របថក៏ល្អឯកអស្ចារ្យ នឹងគន់មើលទៅមុខមាត់ប្រជាជនក៏សុទ្ធតែជាអ្នករីករាយឆ្អែតឆ្អន់ទៅដោយសេចក្តីសុខសាន្ត, ទាំងព្រះរាជាណាចក្រក៏រុងរឿងសម្បូរព្រមពេញទៅដោយរបស់ដ៏មានតម្លៃ ជាទីគួរមើលគួរឃើញ ។ របស់ដែលអស្ចារ្យជាងគេបំផុតនោះ គឺព្រះរាជវាំងជារបស់ផុតវិស័យ ទុរយោធន៍ដែលមិនធ្លាប់ប្រទះឃើញនៅទីដទៃ ។ ការដែលទុរយោធន៍ទៅឯក្រុងឥន្ទ្របថ គ្រានេះ សង្កេតមើលអាកប្បកិរិយា ក៏ដូចជាភ្ញៀវតាងប្រទេសទាំងពួង ដែលគេតែងទៅកាន់នានាប្រទេសតាមសព្វមួយដង ។ ឯហឫទ័យទុរយោធន៍ពេញពោរទៅដោយសេចក្តីក្រហាយដ៏លើសលប់ ប៉ុន្តែដោយសារបានឃើញរបស់ចម្លែកអស្ចារ្យដូច្នេះ ជាទីដឹកភ្នែកឲ្យមើលទាល់តែភ្លើនភ្លេចខ្លួន ។ នៅវេលាដែលទ្រង់យាងទតមហាស្ថាននោះ កាលព្រះសិរទៅប៉ះទង្គិចនឹងជញ្ជាំង ដែលគេខាត់រលោងរលើបឆ្លុះស្រមោលដូចជាកញ្ចក់ឮសូរក្តាំង ក្នុងកាលដែលទ្រង់ទទូចយាងទៅ



ត្រង់ទីនោះ ដោយស្មានថាជាទីវាលចន្លោះ ដល់ទៅមួយកន្លែងទៀត កាលទ្រង់យាងចេញពីបន្ទប់មួយចូលទៅក្នុងបន្ទប់មួយទៀត ទៅប្រទះលើកន្លែងបន្ទប់ទឹកប្រប៉ា (មាស៊ីនទឹក) ដែលកំពុងខ្ពុរបញ្ចេញសុគន្ធរសព្សូរសា ៗ មានអាការៈដូចជាគ្រាប់ភ្លៀងដ៏ល្អិតធ្លាក់ចុះមកអំពីពិតានស្រោចទទឹកគ្រឿងទ្រង់ជោកអស់, ដល់ទៅមួយកន្លែងទៀតទ្រង់លាត់កញ្ចើញព្រះភូសា ដោយសំគាល់ថាជាអាងទឹក ប៉ុន្តែតាមពិត ទីនោះជាផ្លូវដើរសោះ ជារបស់វិការៈដោយថ្មីដៃជាងធ្វើបញ្ឆោតភ្នែកមនុស្ស ។

សេចក្តីពិតវត្ថុអស្ចារ្យទាំងអស់នេះ មិនមែនជារបស់កើតឡើងដោយសារពួកបាណ្ឌពក្សត្រិយ៍ ប៉ុនប៉ងនឹងធ្វើលលេង ឬធ្វើដើម្បីឲ្យទុរយោធន៍អាម៉ាសមុខនោះទេ ប៉ុន្តែទុរយោធន៍មានសន្តានចិត្តមនុស្សពាលក៏ចេះតែសន្សំរើសយករឿង រញ៉ីករញ៉ុកបន្តិចបន្តួចនោះមកពូតឡើងជាដុំកំភួន ព្រោះទៅប្រទះត្រង់រឿងដែលទ្រង់ល្ងើលកាលណាពួកបាណ្ឌពក៏ទ្រង់សម្រួលកាលនោះ ដោយអត់ទ្រាំមិនបានទ្រង់សម្រួលឃឹក ៗ ដោយភាពជាញាតិស្និទ្ធ មិនមែនទ្រង់សម្រួលភ្អាកក្អាយយ៉ាងកញ្ចះគេនោះទេ ។ ទុរយោធន៍នឹកអៀនខ្មាសណាស់ ក៏រករឿងគុំកួនចងអាឃាតព្យាបាទទៅឯង ៗ ហើយប្រញាប់ស្តេចចេញមកអំពីក្រុងឥន្ទ្របថ លុះមកដល់ព្រះនគរវិញហើយ ក៏ទ្រង់លើកយករឿងដែលបរិវិតក្កនោះមកប្រារព្ធជាមួយ

សកុនិ ជាព្រះបិតុលាថា ៖

«ទ្រង់ សកុនិ ! ខ្ញុំឈឺចិត្តណាស់ ! ពួកបាណ្ឌពជាមនុស្ស អាក្រក់សល់សែន បានរៀបចំប្រុងប្រៀបការចាំធ្វើបាបខ្ញុំ ដោយកលោបាយដ៏ល្អិតសុខុម, មានទេវតាជាប្រធាន ទ្រង់បិតុល ! គំនិតរបស់គេគិតតែមើលងាយខ្ញុំម្យ៉ាងប៉ុណ្ណោះ សេចក្ដីប្រមាថមើលងាយអស់នេះ ជូរចត់ល្វីងជាងផ្លែឈើដែលជូរចត់ល្វីងខ្លាំងណាស់ទៅទៀត វាតាំងចិត្តមើលងាយប្រមាថគ្នាមែន ៗ ហេតុនោះ បានជាពួកវាខំដើរតាមខ្ញុំស្រចុះស្រឡើង ដូចជាសុនខចោមរោមជើងដំរី ដើម្បីនឹងបានឃើញហេតុភេទដែលវាក្លែងធ្វើទុកបម្រុង គឺវាចាំគន់មើលតែខ្ញុំភ្លាត់ជើងដួលតិតដួលត្វង ។ ឯអារឿងដួលនេះ វាក៏សំខាន់ណាស់ដែរ ដូចជាធ្លាក់អំពីទីខ្ពស់រលាត់ដៃជើងអស់ក្រែល ។ ឯព្រះរាជហាឫទ័យនៃព្រះជនកខ្ញុំសោតទៀត ក៏ត្រជាក់ល្ហឹមដោយជរាភាពល្បៀតល្បៀន ឥឡូវនេះទ្រង់មិនអាចនឹងត្រិះរិះដោះស្រាយប្រស្នា ដែលជំពាក់ឆ្វាក់ទាក់ទិនចាក់ស្រេះនឹងល្អិតសុខុមបានឡើយ ប៉ុន្តែរឿងនេះអស់យើងរាល់គ្នាដែលជាកូនប្រុសមានដៃមានជើងគ្រប់បរិបូណ៌ មិនត្រូវនៅស្ងៀមចាំមើលតែបំណាំទេ ឬទ្រង់យល់ដូចម្ដេច ? ព្រះជនកលោកជរាណាស់ហើយ ទ្រង់តែស្ដាប់ទីប្រឹក្សាយ៉ាងអព្យាក្រិត ឯទីប្រឹក្សានោះសោត នឹងទុកចិត្តវា ក៏ប្រហែលគ្នានឹងទុកចិត្តអាសិរពិសដែរ, អាពួកចង្រៃវាលក់ម្ចាស់ឯងទាល់តែទ្រម វាទូលណែនាំឲ្យព្រះជនកបែង



ចែកព្រះរាជអាណាចក្ររបស់ខ្ញុំឲ្យទៅពួកបាណ្ឌពពាក់កណ្ដាល ដែលគេគ្មានសិទ្ធិ ឬមុខក្រសួងនឹងត្រូវបានសោះឡើយ, ព្រះជនកលោកគំនិតស្រាលណាស់ បើប្រសិនជាត្រូវគេនិរទេសឲ្យចេញពីព្រះរាជវាំងទៅម្ដង ប្រហែលជានឹងទ្រង់ជ្រាបព្រះអង្គថា « ឱ ! នេះទោសព្រោះតែចិញ្ចឹមអាសិរពិសទុកមួយក្រោលធំនេះឯង» ។ ខ្ញុំនិយាយមកប៉ុណ្ណេះ ព្រោះជាបន្ទុកផ្ទាល់ខ្លួន ព្រះបិតុលក៏បានឃើញច្បាស់នឹងព្រះនេត្រស្រាប់ហើយថា ពួកអធម្មសេនាបតីរបស់យើងបានកើបកាយព្រះរាជ្យទ្រព្យ អំពីព្រះឃ្លាំងផ្ទុកផ្ញើរចាក់ទៅឲ្យពួកបាណ្ឌពប៉ុន្មាន ? ខ្ញុំមិនមែនជាកូនស្រី នឹងមកដេកយំហ៊ី ៗ តាមសភាពជាអ្នកចិត្តទន់ខ្សោយនោះទេ, ខ្លួនខ្ញុំចំជាកូនប្រុសពិតប្រាកដខ្ញុំនឹងច្បាំងឲ្យទាល់តែផុតដង្ហើមអស្សាសបស្សាសជាទីបំផុត, តែចង់ក្របែលអាពួកចង្រៃអប្បល័ក្ខណ៍អស់នេះជាមុនសិន រួចចាំស្លាប់ទៅតាមការចុះ ។ ខ្ញុំគ្នេរឃើញកម្លាំងកងទ័ពរបស់យើង ក្នុងវេលានេះទន់ខ្សោយណាស់ មិនល្មមនឹងធ្វើការដណ្ដើមពិជ័យយុទ្ធកណ្ដាលសមរភូមិជាមួយនឹងសឹកសង្គ្រាមទេ ព្រោះវាមានកម្លាំងរឹងឫទ្ធិណាស់ មានទាំងពួកសម្ព័ន្ធមិត្រជិតខាងជាជំនួយក៏ច្រើនផ្លូវទៀតផង ឯសេចក្ដីថ្កើងរុងរឿងក្នុងប្រទេសរបស់គេនោះ ជាគ្រឿងធ្វើឲ្យផ្សារកាំក្នុងភ្នែកណាស់ ស្មើដូចជាកន្ទុយថ្លែនដែលកើតក្នុងភ្នែក, ខ្ញុំចង់តែស្លាប់ទៅវិញប្រសើរជាជាងរស់នៅ ដោយសេចក្ដីអប្បយសយ៉ាងនេះ បើ

ទុកជាខ្ញុំនឹងមានអាយុរស់នៅ ដូចជាជីវិតសត្វក្អែក ក៏តាមការចុះ» ។

សកុនិ អង្គុយស្តាប់រឿងផ្តេសផ្តាសនេះរហូតទៅ ឥតឆ្លើយឆ្លងជាអ្វីដល់មួយមាត់សោះឡើយ ទាល់តែទុរយោធន៍ចរចាចប់សព្វគ្រប់ ។ សកុនិជាខ្ញុំរាជការធ្លាប់តែប្រចុបប្រចែងម្ចាស់ ហើយនឹងចាក់បណ្តោយតាមម្ចាស់ ស្ទាត់ក្នុងការអង្គុយស្តាប់ស្ងៀម ៗ នឹងស្ទាត់ក្នុងវិធីប្រតិបត្តិ មិនឲ្យទាស់អធ្យាស្រ័យម្ចាស់ កាលបានឃើញទុរយោធន៍ខ្វាល់នឹងពួកព្រះញាតិខ្លាំងណាស់ជាឱកាសនឹងបំពេញឡើងឲ្យដល់ការ, គេក៏ក្អែពិសដាក់បន្ថែមទៅទៀត ឲ្យម្ចាស់រឹតតែក្តៅក្រហាយលើសពីមុនថា ៖

«ទ្រង់មានបន្ទូលនេះគាប់គួរហើយ មើលទៅមិនងាយកាច់កម្លាំងពួកបាណ្ឌពបានឡើយ ព្រោះមានប្រទេសតូចធំជាច្រើនស្រឡាញ់រាប់អានគេ ប៉ុន្តែត្រង់ដែលទ្រង់ត្រាស់ថា «ស្លាប់ទៅវិញប្រសើរជាជាងរស់នៅដោយសេចក្តីអប្បយស» នេះជាព្រះរាជតម្រិះដ៏ខុសស្រឡះ, ដ្បិតសេចក្តីអប្បយសប្រៀបដូចអាកាសធាតុ ក៏ថាបាន បើមិនដូច្នោះទេ គឺដូចជាមុខដំបៅអាចនឹងរក្សាឲ្យសះជាបានកាលមិនយូរ, គំនិតម្យ៉ាងបានដុះដាលឡើងក្នុងចិត្តខ្ញុំ សូមទូលឲ្យទ្រង់ជ្រាបនូវឧបាយម្យ៉ាង ឃើញបានការជាពិតប្រាកដថា យុធិស្ឋិរជាអ្នកចូលចិត្តលេងស្កាណាស់ គេតែងដឹងឮរាល់គ្នាស្រាប់ហើយចំណែកខាងខ្ញុំ ទ្រង់ក៏ធ្លាប់បានជ្រាបស្រាប់ហើយដែរ ថាជាអ្នកស្ទាត់



ក្នុងការលេងស្កាយ៉ាងដូចម្តេច យុធិស្ឋិរនៅខ្ចីដៃណាស់ ខ្ញុំអាចនឹងលេងយកជ័យជម្នះបានដោយឧបាយរាប់ពាន់ផ្លូវគឺខ្ញុំនឹងលេងដោយកូនស្កាបង្កប់សំណឲ្យធ្ងន់ ជន្លឲ្យបានចិត្តខ្លាំងឡើង ៗ ប្រមាណតែត្រឹមពាក់កណ្តាលឡូ ខ្ញុំនឹងធ្វើឲ្យគេហិនហោចទៅតែម្តង នឹងលេងឲ្យអស់សាច់ឈាមរលីងធេងក៏បាន, រឹបយករបស់ទ្រព្យឲ្យអស់ទាល់តែកាន់អំបែងដើរសុំទានគេ ឬនឹងគាបរឹតគាត់ឲ្យតឹងជាងនេះទៅទៀតក៏បានដោយយើងតាំងសន្យាថា «អ្នកចាញ់ត្រូវតែដើរចេញពីព្រះនគរទៅនៅក្នុងព្រៃកំណត់អស់វេលា ១២ ឆ្នាំ» យើងអាចនឹងរំលើងរំលាងសឹកសត្រូវរបស់យើង ឲ្យបរាជ័យអស់រលីងធេង ដោយគំនិតឧបាយកលខាងក្នុងយ៉ាងនេះ មិនមែនចេញមុខទៅច្បាំងគ្នាឮក្តុងក្តាំង បំផ្លាញគ្រឿងយុទ្ធភណ្ឌ ឲ្យខាតបង់ទៅទទេ ៗ នោះទេ» ។

## ភាគទី ៦

## ការលេងស្កាភ្នាល់យ៉ាងធំ

ឥឡូវនេះ ទុរយោធន៍ និងសកុនិ បានរួមគំនិតគ្នាគិតការប្រុងប្រៀបទុករួចស្រេចហើយ ។ លំដាប់នោះទុរយោធន៍ក៏ចូលទៅគាល់ព្រះរាជបិតា ក្រាបចុះទៀបយុគលបាទ ទ្រង់ព្រះកន្សែងអាក់អួលទឹកព្រះនេត្រស្រក់ស្រស្រាក់ស្រោចភក្ត្រា ។ ព្រះរាជបិតាឃើញអាការៈកូនសម្លាញ់ដូច្នោះហើយ ក៏ត្រាស់សួរដេញដោលរកហេតុផល ។

«ព្រះជាម្ចាស់លើត្បូង សូមទ្រង់ជ្រាប ៖ សេចក្ដីល្អនៃក្រុងឥន្ទ្របថរបស់យុធិស្ឋិរ ជាជាងក្រុងហាស្តិនបុររបស់យើង ដែលធ្លាប់តែល្បីល្បាយតាំងពីកាលណាមកហើយ ជាច្រើនភាគណាស់, ទីព្រះឃ្លាំងរបស់គេ ពេញពោរទៅដោយមាស ប្រាក់ កែវកង ពេជ្រនិលចិន្តា ដ៏មានតម្លៃ, រដ្ឋសីមារបស់គេ សុទ្ធសឹងតែប្រាសាទច្រូងច្រាងច្រាលរន្ទាល ហាក់បីដូចជាយោងយឹតយកអំពីស្ថានសួគ៌មកប្រតិស្ឋានទុកនៅទីនេះ, សម្បត្តិទាំងនេះ កាលដើមឡើយ យើងជាអ្នកអបលោកឱ្យគេ ឥឡូវនេះ គេថ្កើងរុងរឿងខ្ពស់ហួសមុខមាត់យើងទៅទៀត ហើយគេធ្វើឫកក្រអឺតក្រទម មើលងាយយើងដូចជាអ្នកព្រៃ, ព្រះករុណា ទូលព្រះបង្គំជាខ្ញុំ ចង់តែស្លាប់បង់ទៅវិញទេ, ជាសេចក្ដី



ពិត តាមស្មានមើល ទូលព្រះបង្គំជាខ្ញុំ តាមដែលបានទទួលសេចក្ដីទុក្ខទោមនស្សទាំងនេះ ប្រហែលជាគ្មានគង់ទ្រង់ជីវិតរស់នៅរហូតមកដល់បានក្រាបទូលរឿងនេះ ឲ្យទ្រង់ជ្រាបទេ ប៉ុន្តែគ្រោះជាទ្រង់សកុនិបានជួយបន្ធោបង់សម្រាលទុក្ខទាំងនេះ ឲ្យឃ្លាតចេញបានខ្លះរាប់ថាជាព្រះគុណយ៉ាងខ្ពស់ កុំអីប្រហែលជា... ទ្រង់បានសម្ដែងបំភ្លឺឧបាយកលយ៉ាងឯក សម្រាប់នឹងកាច់កិនគូបដិបក្ខដែលប្រកួតនឹងយើងឲ្យរលីងរលាយខ្លួនទៅ, ឯលេសនោះទ្រង់សកុនិ ប្រាប់ឲ្យយើងធ្វើយ៉ាងនេះ ត្រូវអញ្ជើញយុធិស្ឋិរមកលេងស្កាភ្នាល់គ្នា ពួកយើងបានត្រៀមការរួចស្រេចហើយ ដែលអាចនឹងធ្វើឲ្យគេបរាជ័យចាញ់យើងរាល់ក្តាររហូតទៅ ទាល់តែទូលព្រះបង្គំជាខ្ញុំ បានរបស់ដែលខូចខាតទៅនោះត្រឡប់មកវិញ គឺថានឹងយករាជអាណាចក្រពាក់កណ្ដាលដែលចែកទៅឲ្យគេនោះវិលមកវិញ បើគ្រោះអាក្រក់ ទូលព្រះបង្គំជាខ្ញុំចាញ់គេ គឺតាមតែយថាកម្មចុះ ទូលព្រះបង្គំជាខ្ញុំសុខចិត្តទទួលបាបគ្រោះដោយតុណ្ហិភាព, ឲ្យគេធ្វើជាព្រះមហាក្សត្រិយ៍ តែមួយអង្គជំនួសទូលព្រះបង្គំជាខ្ញុំទាំងអស់ទៅចុះ ថាបើមិនដូច្នោះទេ ត្រូវឲ្យទូលព្រះបង្គំជាខ្ញុំ បានគ្រប់គ្រងអាណាចក្រទាំងមូល ដោយមិនចាំបាច់បែងប៉ានឲ្យអ្នកណាមួយឡើយ, ការដែលឲ្យធ្វើជាធំទាំងពីរនាក់នោះ ផ្កាយពីរដួងនឹងត្រាច់ចរទៅក្នុងរាសីតែមួយផ្លូវជាមួយគ្នាមិនកើតទេ ព្រះករុណា!» ទុរយោធន៍ក្រាបទូល ។

ធ្វតរាស្ត្រត្រាស់តប ! «កូនសម្លាញ់មាសឪពុក ! សេចក្ដីសោកកើតមានឡើង ព្រោះទោសៈ ឯទោសៈសោតបាននឹងចិត្តវក់មួយរំពេច ៗ ប៉ុណ្ណោះ ម្ដេចក៏បាបណ្ដោយឲ្យភ្លើងពិរោធចូលមកដុតរោលហឫទ័យរបស់បាឲ្យក្រៀមក្រំទៅថ្វី ? ម្ដេចមកយាយីបងប្អូនឯងទៀត ? គេបានក្តីលំបាកតោកយ៉ាកមកពីមុននោះ ក៏ល្មមហើយ, បណ្ដោយឲ្យគេនៅជាសុខខ្លះផងកូន ! ការដែលស្ទះស្វែងរករឿងទៅលើអ្នកមានអំណាចរាជស័ក្តិ ក៏ហាក់ដូចជាដាស់រាជសីហ៍ ដែលកំពុងដេកលក់ឲ្យភ្ញាក់ឡើង, អារឿងភ្នាល់ បាកុំនាំមកតំណាលឲ្យបិតាឮ បិតាស្អប់ឈ្មោះបោះសម្លេងវាណាស់ វាប្រាប់ហេតុតែត្រង់សេចក្ដីវិនាស និងគ្រោះថ្នាក់ប៉ុណ្ណោះ, បិតាព្រឺក្បាលណាស់ កាលមកគិតនឹងអនុញ្ញាតឲ្យបានលេងល្បែងគ្រានេះ, តែបាចូរសួរវិទូរមើលសិន តើគេនឹងមានសេចក្ដីយល់ឃើញដូចម្ដេចក្នុងរឿងនេះ» ។

វិទូរ មិនបង្អង់ឲ្យសួរទាន់ ក្រោកឈរឡើងភ្លាម ទទូលសូមព្រះរាជវរោសកាសរួចហើយ សម្ដែងសេចក្ដីយល់ឃើញរបស់គេថា «ទេវព្រះអង្គ រមែងទ្រង់ជ្រាបហើយថា «ទូលព្រះបង្គំមិនធ្លាប់ជាអ្នកប្រចុបប្រចែងអ្នកណាទេ» សំដីទូលព្រះបង្គំជាខ្ញុំ ច្រើនតែឲ្យទោសដល់ទូលព្រះបង្គំវិញជាញយ ៗ មកហើយ, គ្រានេះទៀតដែរ ព្រោះលោកថា «ពាក្យពិតវែងស្លែង» ទូលព្រះបង្គំជាខ្ញុំតោងតែសូមថ្លែងតាមមតិរបស់ខ្លួន» «លោភចិត្តរបស់ម្ចាស់យើង ដែលទៅជណ្ដើមទ្រព្យ



សម្បត្តិបងប្អូនឯង, លេសដែលទ្រង់ប៉ុនប៉ងនឹងធ្វើទៅនោះ សុទ្ធតែជាហាយនកម្ម និងអំណោយផលអាក្រក់ គួរឲ្យស្ញែងណាស់, ទូលព្រះបង្គំជាខ្ញុំយល់ឃើញថា ជាមុខក្រសួងរបស់ទូលព្រះបង្គំជាខ្ញុំតែក្រាបទូល ដាស់តឿនព្រះសតិទ្រង់ព្រះករុណា» ។

សេចក្ដីមិនពេញព្រះហឫទ័យ ឲ្យលេងស្កាភ្នាល់របស់ព្រះរាជានឹងពាក្យយល់ទាស់របស់វិទូរនេះ មិនធ្វើឱ្យទុរយោធន៍សោយមនោមនះទៅបានឡើយ ត្រឡប់ជាទ្វេសេចក្ដីឫស្យាឲ្យរឹតតែចាស់ក្លាឡើងទៀត ។

ចំណែកឯ យុធិស្ឋិរជាអ្នកប្រកបដោយគុណសម្ប័ទផ្សេង ៗ ក៏មែនហើយ ប៉ុន្តែនៅទន់ខ្សោយម្យ៉ាង គឺត្រង់ការសព្វព្រះហឫទ័យលេងស្កាណាស់ ចំណង់នេះជាមារដ៏សំខាន់ ដែលព្រះអង្គមិនអាចតស៊ូនឹងវាបានឡើយ ។ កាលបើទ្រង់បានជ្រាបថា មានល្បែងភ្នាល់ស្កានៅទីណា ក៏ចេះតែស្ដេចទៅទត ឬទៅក្រសាលជាមួយនឹងគេនៅទីនោះជាដរាប ព្រោះហេតុនោះ កាលទុរយោធន៍អញ្ជើញទៅក្រសាលការភ្នាល់ស្កា ទ្រង់យល់ឃើញថាជាកិត្តិយសមួយយ៉ាង គួរតែទទួលអញ្ជើញទៅភ្នាល់នឹងគេ ទើបស្ដេចចេញចាកឥន្ទ្របថបុរីនាំយកទាំងព្រះអនុជ ៤ អង្គ និងព្រះជននីរាជា, ទ្រៅបទី ទៅជាមួយផង ។

ចាប់ក្រសាលភ្នាល់ស្កា ៖ គ្គារជំបូង យុធិស្ឋិរចាញ់មួយពាន់

ល្បែល, ក្នុងក្តារត ១ ទៅមុខ ក៏ទន់ជាងគេជាដរាប ក្នុងថ្ងៃគ្រោះមិនល្អនោះ ។ ថ្ងៃព្រឹកឡើងទ្រង់ក្រសាលទៀត ក៏ចេះតែចាញ់គេរាល់ក្តារទៀត, កាលបើចាញ់គេច្រើនក្តារណាស់ទៅ ក៏កើតក្តៅក្រហាយកាន់តែខ្លាំងឡើង ៗ, មាសពេជ្រ, សេះ, ដំរី, រថ, ទ្រង់យកមកដាក់ភ្នាល់នឹងគេទាល់តែអស់រលីង របស់ទាំងនេះរបូតផុតពីដៃទៅអស់ទៀត ។ លំដាប់នោះទ្រង់យកព្រះរាជទ្រព្យក្នុងព្រះឃ្លាំងមកតាំងភ្នាល់ រួចពីនេះទ្រង់យករាជអាណាចក្រមកដាក់ភ្នាល់ទៀត របស់ទាំង ២ មុខនេះក៏រលាយទៅតាមគ្នាដូចមុន ទោះបីម្ល៉ឹងហើយ សេចក្តីក្រហាល់ក្រហាយក្នុងការល្បែង ក៏នៅតែមិនស្រាកស្រន់ ទើបទ្រង់លើកយកព្រះអនុជទាំង ៤ អង្គដាក់ភ្នាល់ទៀត ចាញ់អស់ព្រះអនុជទាំង ៤ អង្គហើយ ទ្រង់ដាក់ព្រះអង្គឯងភ្នាល់ទៀត ក៏ចាញ់គេទៅ ក្នុងទីបំផុតទ្រង់ដាក់នាងទ្រៅបទី នាងនេះក៏របូតផុតពីដៃបាត់ស្រមោលទៅទៀត ។ ជាការអប្បយសអាម៉ាស់មុខយ៉ាងបំផុត ភីស្មៈ, ទោណ និង វិទូរ អង្គុយមើលតែមុខគ្នាធ្វើភ្នែកភ្លឹះ ៗ ក្នុងចិត្តសែនស្លុតសែនសង្វេគយ៉ាងក្រៃលែង ។ ចំណែកកណ៌ទុហាសាសនៈ និងពួកអ្នកគំនិតកោងអប្បល័ក្ខណ៍ទាំងប៉ុន្មានអង្គុយលេង ទឹកមុខញញឹមដោយឃើញផ្លូវបានប្រៀបយ៉ាងធំដូចមនោរថហើយ ។

ទីបំផុតនៃការដែលរាប់ថា ចាញ់ឈ្នះគ្នានោះ ស្រេចនៅត្រឹមរូបនាងទ្រៅបទី ទុរយោធន៍ត្រាស់ប្រើឲ្យវិទូរទៅនាំយកខ្លួននាង



ទ្រៅបទីមកក្នុងបន្ទប់ទីប្រជុំរដ្ឋមន្ត្រី ដោយទ្រង់យល់ឃើញថា វេលានេះនាងមិនមែនជារាជិនីទេ នាងធ្លាក់ទៅជាទាសីវិញហើយ ។ វិទូរក្រាបទូលអង្វរថា «សុំព្រះបាទទ័យទ្រង់កុំធ្វើដល់ម្ល៉ោះពេក ការដែលនឹងនាំនាងទ្រៅបទីមកកាន់ទីនេះ ជាការប្រមាថមើលងាយនាងហួសហេតុដ៏សមគួរ ជាហេតុឲ្យពួកបាណ្ឌពកើតទោសោខ្ទួលខ្នាញ់ឡើង មុខជានឹងបណ្តាលឲ្យកើតហេតុធំដុំជាមិនខាន ។ រឿងនេះ បើយើងចេះតែខំមានះធ្វើទាំងលោភទៅ សូម្បីតែទារកតូចតាចក្នុងប្រទេសឥន្ទ្របថ ក៏អត់ទ្រាំពុំបានដែរ» ។

ទុរយោធន៍ បញ្ចេញសំដីគ្រានោះបោះបោកឲ្យវិទូរជាច្រើនហើយត្រាស់ប្រើឲ្យរាជបុរស ទៅកោះយកខ្លួននាងទ្រៅបទីមកជាយ៉ាងប្រញាប់ ។ វិទូរជាមនុស្សស្លូតបូត សុចរិត ចេះតែដកដង្ហើមធំរិះគិតតែក្នុងចិត្តខ្លួនថា «ទុរយោធន៍បោះបង់ចោលធម្មចរិយាអស់រលីងហើយ, អំពើទុច្ចរិតជាផ្លូវត្រង់ទៅអបាយ, ឥឡូវទុរយោធន៍កកិលនឹងចុះទៅរកផ្លូវនោះហើយ» ។

គ្រានោះ ទ្រៅបទីទេវី កំពុងតែគង់នៅក្នុងបន្ទប់,បន្តិចលេចរាជបុរសទៅដល់ បើកទ្វារគ្រោរចូលទៅ ទូលប្រព្រឹត្តហេតុ ឲ្យនាងជ្រាបតាមព្រះរាជតម្រាស់ ។ទ្រៅបទីធ្លាក់ព្រះហឫទ័យក្តុក ប៉ុន្តែខំតម្កល់ព្រះសតិសម្បជញ្ញៈទាន់ មានបន្ទូលទៅនឹងសារ័ណទូត (អ្នកមកកោះខ្លួន) ថា «ម្នាលនាយត្រចៀកយើងបានស្តាប់សំដី ដែលអ្នកឯង

និយាយដូច្នេះមែនឬ ? ព្រះរាជស្វាមី[១] ត្រាស់នឹងអ្នកដូច្នេះឬ ? ទ្រង់អស់ព្រះរាជ្យទ្រព្យហើយឬ ? បានយករាជិនីទៅដាក់ភ្នាល់នឹងគេឯងទៀត ? ទ្រង់វិកលសតិទៅហើយឬអី ? » ។

«ព្រះរាជ្យទ្រព្យអស់រលីងធេង ទៅហើយក្រាបទូល ! ព្រះបាទយុធិស្ឋិរបង់ខាតសព្វសារពើ បណ្ដាដែលមាននៅក្នុងការគ្រប់គ្រងរបស់ព្រះអង្គ រហូតដល់មកុដរាជ្យ ព្រះអនុជ ព្រះរាជិនី ។ល។ សព្វគ្រប់ទាំងអស់ហើយ» សារ័ណទូត ក្រាបទូល ។

ទ្រៅបទីក្រោកឈរ ទ្រង់មានសវនីយ៍ដោយភ្លើងទោសោថា «បើព្រះរាជារបស់យើងដាក់ព្រះអង្គជាវត្ថុសម្រាប់ភ្នាល់នឹងគេ តាំងអំពីដើមទីទៅហើយសោត ព្រះអង្គក៏ក្លាយទៅជាទាសៈរបស់គេមួយរំពេចទៅហើយ ចាប់ពីត្រឹមកាលនោះមក ព្រះអង្គក៏អស់អំណាចនឹងមកយកខ្លួនយើងទៅដាក់ភ្នាល់ទៀតហើយ ព្រោះហេតុថា ធម្មតាជាតិជាមនុស្សខ្ញុំកញ្ជះគេ តែងតែគ្មានទ្រព្យសម្បត្តិ និងឥតអំណាចលក់ដូររបស់អ្វីបានឡើយ ព្រោះហេតុនេះ គាត់ចូរនាំយកពាក្យយើងនេះទៅក្រាបទូលព្រះភស្ដារបស់យើងផងថា «គ្មានអ្នកណានឹងមានអំណាចត្រូវបានទ្រៅបទីទេ» ។

រាជទូតត្រឡប់ទៅដល់ទីប្រជុំរដ្ឋមន្ត្រីវិញ ក៏នាំសំដីបញ្ឆោះ

១)- ទ្រៅបទី កាលពីដំបូងបានជាទេពីអរជុន, ដល់វេលាក្រោយមកឮថា បានជាទេពីរបស់យុធិស្ឋិរវិញ ហើយជារាជិនីប្រទេសឥន្ទ្របថ ។



ពោះសោករបស់ព្រះនាងទ្រៅបទីក្រាបទូលទុរយោធន៍ ទុរយោធន៍ក៏ខ្នាល់ក្ដួងដូចភ្លើងអគ្គិសនី ត្រាស់ប្រើទុហាសាសនៈជាអនុជ ឲ្យចាប់អូសយកនាងមកគាល់ជាយ៉ាងប្រញាប់ ។

ទុហាសាសនៈទៅដល់ដំណាក់ភ្លាម ចូលទៅក្នុងបន្ទប់នាងទ្រៅបទី ហើយថ្លែងព្រះរាជឱង្ការថា «ឱ !ក្សត្រីបញ្ចាល ! ព្រះនាងត្រូវគេយកទៅដាក់ភ្នាល់ ឥឡូវនេះ ព្រះនាងធ្លាក់ទៅជារបស់នៃអ្នកឈ្នះហើយ សម្ដេចព្រះជេដ្ឋាទុរយោធន៍ មានព្រះបន្ទូលឲ្យព្រះនាងចូលទៅគាល់ព្រះអង្គដែលជាម្ចាស់របស់ព្រះនាង, តាំងពីពេលនេះជាដើមទៅ ព្រះនាងធ្លាក់ទៅជាបាទបរិចារិការបស់ព្រះបាទទុយោធន៍ហើយ » ។

ទ្រៅបទីទេវី បានទ្រង់ព្រះសណ្ដាប់ពាក្យប្រមាថមើលងាយនេះហើយ ព្រះកាយញ័រចំប្រប់ ដោយសេចក្ដីខ្លាច នឹងក្រេវក្រោធក្រៃលែង ។ ព្រះនាងយកព្រះហស្តខ្ទប់ព្រះភក្ត្រមិនឲ្យទុហាសាសនៈមើលឃើញអាការៈដែលពិកលពិការ, ព្រះហទយវត្ថុញ័រតឹកៗ រញ្ជួយទាំងសកលកាយ ។ ខណៈនោះ ព្រះនាងលោតស្ទុះចេញអំពីកន្លែងប៉ុនប៉ងនឹងរត់ចេញខាងក្រៅបន្ទប់ ប៉ុន្តែទុហាសាសនៈជាមនុស្សកោងកាចអប្រិយ ក៏ចាប់កន្ត្រាក់កេសារបស់ព្រះនាងដែលកំពុងតែរន្ធត់អស់អង្គ ឃាក់បីដូចស្លឹកព្រឹក្សាខ្ចីត្រូវពាយុបក់បោកមក ។ គេអូសទាញយកព្រះនាងទៅ ឃាក់ដូចនាយយមបាលភើចកន្ត្រាក់

សត្វនរក ។ ព្រះនាងលុតជង្គង់ហើយលើកកប្រណម្យសុំអង្វរ ទុហាសាសនៈ ថា «អើអ្នក ! អ្នកកុំមកប៉ះពាល់ដល់រាងកាយខ្ញុំ ដោយដៃរបស់អ្នក ដែលជាប់មន្ទិលសៅហ្មង, អ្នកតែងបានជ្រាបហើយថា «សក់របស់ស្ត្រីស័ក្តិសិទ្ធិ សុភាពស្ត្រី កាលបើមានគ្រឿងតាក់តែងកាយរយីករយាកដូច្នេះ នឹងចូលទៅរកអ្នកធំដូចម្តេចកើត » ។ ប៉ុន្តែ ទុហាសាសនៈ ជាមនុស្សប្រកបដោយនិស្ស័យចិត្តថ្លើមរបឹងរឹងរូស មិនព្រមស្តាប់ពាក្យអង្វរកររបស់នាងសោះ គេឆ្លើយទៅរកព្រះនាងវិញថា «បើទុកជានាងមានគ្រឿងបិទបាំងខ្លួនក្តី គ្មានសោះក្តី យើងឥតត្រូវការទទួលដឹងឮទេ នាងត្រូវដើរតាមយើងទៅឲ្យយ៉ាងលឿន នឹងបង្អែបង្អង់ ឲ្យយឺតយូរមិនបានសោះជាដាច់ខាត» ។

គ្រានោះ ទ្រៅបទី ទោះបីមិនស្ម័គ្រចិត្តនឹងទៅតាមគេក៏ដោយ ក៏តោងតែទៅយ៉ាងរយីករយាក សោតឯសក់ក្បាលក៏របូតរលូតក្រញាញ់ក្រញាស ព្រោះត្រូវគេចាប់អូសទៅដោយកំហាល់, ព្រះនេត្រពេញពោរនៅដោយអស្សុជល ស្រក់ស្រស្រាក់ស្រោចភក្ត្រាសុតាស្រី ។ ទ្រៅបទីទៅដល់ទីចំពោះព្រះភក្ត្រអ្នកធំទាំងឡាយហើយ ព្រះនាងក៏អភិប្រាយសូមទោសអ្នកធំជាមុខថា «បពិត្រលោកដ៏ចម្រើនទាំងឡាយ សូមលោកឲ្យអភ័យដល់ខ្ញុំ ដែលបានឈានចូលមកក្នុងទីប្រជុំនេះ ទាំងសំល្បៀកបំពាក់មិនគួរគប្បី» ។

ភីស្មៈ, ទោណា និងអ្នកធំឯទៀតជាច្រើននាក់ កាលបើក្រឡេក



ទៅឃើញទ្រៅបទីហើយ ក៏ដាក់ភក្ត្រជ្រប់ ដោយនឹកអៀនខ្មាសជួសនាង និងអាណិតអាសូរដល់នាងជាពន្លឹក ។ ចំណែកទុរយោធន៍វិញ ដែលជាអ្នកមាននិស្ស័យរបឹង ឥតចិត្តអាសូរករុណាដល់នាងបន្តិចបន្តួចសោះ បែរជាស្រែកសន្ទាប់បង្គាប់ដោយកំហាល់ថា «ទុហាសា-សនៈ ចូរអ្នកសម្រាតសំពត់នាងចេញឲ្យដល់ស្បែក, សម្រាតឲ្យអស់រលីងធេងពីខ្លួន ឲ្យបងសម្លឹងមើលឆោមឆវីរបស់នាង ក្នុងយាមអាក្រាតកាយននលនេះម្តង » ។

ការដ៏លាមកឥតខ្មាសដូច្នេះ បណ្តាលឲ្យអ្នកអង្គុយនៅក្នុងទីប្រជុំនោះកើតឆុកឆួលទោសោឡើងតែរាល់គ្នា ទាល់តែម្នាក់ ឬពីរនាក់ក្នុងពួកនោះ យកដៃទៅចាប់ក្តាប់ដងក្រប៊ី ។ ឯអាការៈដែលគេលូកដៃទៅចាប់ដងក្រប៊ីនោះ មើលទៅហាក់ដូចជាធ្វើទោសចិត្តរបស់គេ ឲ្យធូរស្រាលរសាយទៅបានខ្លះ បាត់ណែនតឹងក្នុងដើមទ្រូងគ្រាន់បើ ។

ដោយសន្តានចិត្តជាមនុស្សពាល ជ្រោកជ្រាកប្រាសចាកមេត្តាករុណា ទុហាសាសនៈបានចូលទៅបោចពោចសម្រាតសំពត់អាវទ្រៅបទីតាមបង្គាប់ព្រះជេដ្ឋា ។ ទ្រៅបទីស្រែកថា «ចូរស្តាប់ខ្ញុំម្ចាស់ ! ចូរជួយខ្ញុំម្ចាស់ផង លោកអ្នកធំទាំងឡាយ ! លោកក៏មានភរិយា និងបុត្រីដូចគ្នាដែរ, លោកនឹងបណ្តោយឲ្យស្ត្រីអ្នកមានព្រហ្មចារិយៈ ត្រូវគេកំហែងលេងជាល្បែងនៅមុខអស់លោកដូច្នេះឬ ? ចូរជួយខ្ញុំម្ចាស់

ផងព្រះអង្គ ! ចូរជួយឲ្យរួចអំពីសេចក្តីអាសអាភាសអស់នេះផង ព្រះគុណអើយ ! » ។ ស្វាត់ច្រៀបមួយស្របក់ ទ្រៅបទីស្រែកម្តងទៀតថា «ម្តេចក៏ស្ងៀមស្ងាត់រាល់គ្នាយ៉ាងនេះ ? គ្មានអ្នកណាម្នាក់ក្នុងពួកលោកលើកអង្គុលីឡើងការពារសម្មានស័ក្តិនៃស្ត្រី ដ៏រកមន្ទិលគ្មាននេះហើយឬ ? សេចក្តីល្បីល្បាយខ្ទរខ្ទាយរបស់ជាតិកុរុ, កិត្តិគុណចាស់របស់ភារតវង្សសាបសូន្យអស់រលីងទៅហើយ ឬអ្វី ? ក្សត្រិយ៍ទាំងឡាយ លែងធ្វើជាអ្នកចម្បាំងហើយឬអ្វី ? ស៊ូតែនាំគ្នាអង្គុយស្ងៀម មើលអំពើដ៏លាមកយ៉ាងនេះកើតដែរឬទេ ? » ។

ភីស្មៈក្រេវក្រោធមុខឡើងក្រហម, ទោណខាំមាត់សង្កៀតធ្មេញក្រឹត ក្តាប់ដៃប្រុងនឹងដាល់, វិទូរថ្ងូរ ហ៊ឺ ៗ យកចិត្តជួយ, ចំណែកឯភីម (ព្រះអនុជយុធិស្ឋិរ) គ្រវីដំបងស្រែកប្រកាសជាពាក្យស្បថស្បែទុកថា «នឹងហុតឈាមទុហាសាសនៈ ហើយនឹងយកជីវិតទុរយោធន៍ ឲ្យបានដោយដំបងនេះ មុនថ្ងៃដែលខ្លួនគេស្លាប់ » ។

ទុរយោធន៍ធ្វើឫកសម្តែងអំណាចយ៉ាងសម្បើម ដោយមានជ័យជម្នះ បែរមកត្រាស់នឹងយុធិស្ឋិរថា ៖

«ទ្រង់ចូរថ្លែងតាមពិតមកមើល, ព្រោះទ្រង់ធ្លាប់តែបញ្ចេញវាចាទៀងទាត់រាល់វេលា, ទ្រង់បង់រាជអាណាចក្រ, បង់អនុភាតា, បង់ខ្លួនប្រាណរបស់ទ្រង់, មិនតែប៉ុណ្ណោះ ថែមទាំងបង់មហេសីមកខ្ញុំទៀត មែនឬមិនមែន? » ។



យុធិស្ឋិរ មិនហើបមាត់ ។ ឯកណ៌នឹកអស់សំណើច ក៏សើចក្អាក ៗ ។ តែភីស្មៈអង្គុយសម្រក់ទឹកភ្នែកព្រិច ៗ មិនចេញស្តីជាអ្វីសោះ ។

វេលានោះ ព្រះបាទធ្រឹតរាស្ត្រកំពុងនៅក្នុងព្រះរាជវាំង មិនបានទ្រង់ជ្រាបហេតុភេទ ដែលកើតឡើងក្នុងទីប្រជុំរដ្ឋមន្ត្រីនោះឡើយ ។ ព្រាហ្មណាចារ្យទាំងឡាយ កំពុងតែស្វាធ្យាយវេទធម៌វត្តល្ងាច ។ ពេលនោះ ទ្រង់ឮសូរស័ព្ទសម្រែកសិង្គាល (ឆ្កែចចក) លូក្នុងព្រៃប្រាប់ហេតុដ៏អាក្រក់កើតឡើងនោះ ទ្រង់ក៏ធ្លាក់ព្រះហឫទ័យភ្ញាក់ ព្រះកាយញ័រញ្ញើក ៗ, មួយស្របក់ វិទូរចូលទៅដល់ក្រាបទូលប្រព្រឹត្តហេតុតាមដែលទុរយោធន៍បង្កបង្កើតឡើង កាលបានទ្រង់ជ្រាបហេតុដ៏ជាអប្បមង្គលដូច្នោះហើយ ក៏ទ្រង់ព្រះកន្សែង ត្រាស់ព្រះសូរសៀងញ័ររន្ធ័នថា «ឱ អាកូនកម្ម ! វាធ្វើឲ្យព្រះរាជា ទ្រុបទកើតសេចក្តីអាសអាភាសហើយ ដោយហេតុវាហ៊ានប្រមាថមើលងាយធីតារបស់គេ ដ៏ជាវិសុទ្ធិកន្យា, សូមឲ្យពាក្យភាវនារបស់បិតាដែលកំពុងតែព្រួយសោយទុក្ខសោកនៅវេលានេះ ចូរអភិបាលរក្សាការពារភយន្តរាយនៃព្រះជាម្ចាស់ដ៏ធំលើស្ថានសួគ៌ តាមដែលបានឮហេតុភេទអាក្រក់នោះចុះ »។

សម័យនោះ មានអ្នកនាំស្តេចទៅរកនាងទ្រៅបទី ទ្រង់ត្រាស់នឹងនាងថា «ម្នាលបុត្រីនៃវិសុទ្ធរាជា ! នាងជាទីសម្លាញ់ដូចដួង

ហឫទ័យរបស់បិតុលៈ ឱអនិច្ចា ! បុត្ររបស់បិតុលៈ បានធ្វើសេចក្ដីកំហឹងដល់នាងជាទម្ងន់ នាងចូរឲ្យអភ័យដល់វាផងចុះ និងសូមទោសព្រះជាម្ចាស់លើស្ថានសួគ៌ កុំឲ្យធ្លាក់លើត្បូងរបស់វា, នៃក្មួយសម្លាញ់របស់បិតុលៈ ! នាងនឹងប្រាថ្នាចង់បានវត្ថុអ្វី បិតុលៈនឹងប្រទានឲ្យនាងគ្រប់យ៉ាងតាមបំណង» ។

ទ្រៅបទីក្រាបទូលថ្វាយពរជ័យចំពោះព្រះរាជា ដ៏ទ្រង់នូវមេត្តាគុណ និងទូលសូមសេចក្ដីមេត្តាប្រោសប្រណីជួយឲ្យយុធិស្ឋិរ រាជស្វាមីរួចពីទាសភាព ។ ទ្រង់ក៏ប្រទានឲ្យរួចមួយរំពេច ។ ព្រះបាទធ្ឫតរាស្ត្រ សូមឲ្យទេវីសម្ដែងប្រាប់សេចក្ដីប្រាថ្នាយ៉ាងដទៃតទៅទៀត ។ នាងក្រាបទូលសុំឲ្យលើកទោសអនុភាតារបស់ព្រះភស្ដានិងទូលសូមឲ្យបានសេះ, រថ, អាវុធរបស់គេមកវិញ ។ សេចក្ដីប្រាថ្នារបស់នាងគ្រាទី ២ នេះ ព្រះបាទធ្ឫតរាស្ត្រ ក៏ទ្រង់ព្រះរាជទានឲ្យជាយ៉ាងប្រញាប់ រួចទ្រង់សូមឲ្យនាងប្រាប់សេចក្ដីប្រាថ្នាគ្រាទី ៣ តទៅទៀត» ។ ទ្រៅបទីក្រាបទូលថា «ខ្ញុំម្ចាស់ជាធីតាក្សត្រិយ៍, ខ្ញុំម្ចាស់អស់ប្រាថ្នារបស់ដទៃទៀតហើយ ប្រាថ្នាតែត្រឹម ២ ដងប៉ុណ្ណោះក៏ល្មមការនឹងប្រាថ្នាសព្វសារពើទៅទៀតមិនគួរទេ ព្រះករុណា!» ។

បាណ្ឌពក្សត្រិយ៍បានអនុញ្ញាតឲ្យត្រឡប់ទៅក្រុងឥន្ទ្របថវិញ។ នៅពេលចេញដំណើរផុតអំពីក្រុងហាស្ដិនបុរទៅនោះ ទុរយោធន៍ក៏ចូលទៅគាល់ព្រះរាជបិតាភ្លាម ក្រាបទូលបន្ទោសព្រះបិតាដោយ



ចិត្តក្រេវក្រោធថា «ល្អងធូលីអនុញ្ញាតឲ្យពួកបាណ្ឌពទាំង ៥ រូបខ្លួនទៅជាសុខសាន្ត ឯគំនិតគេគិតតែពីធ្វើសង្គ្រាមសងសឹកនឹងយើងវិញជាមិនខាន ព្រោះហេតុនេះ សូមឲ្យទូលព្រះបង្គំជាខ្ញុំភ្នាល់ស្កានឹងគេមួយគ្រាទៀត ហើយដាក់កម្រិតការភ្នាល់ម្ដងនេះថា «បើអ្នកណាចាញ់ អ្នកនោះនិរទេសឲ្យទៅនៅព្រៃ កំណត់អស់វេលា ១២ ឆ្នាំ លុះផុតកំណត់នោះហើយ ត្រូវតែពួនមុខនៅក្នុងទីសន្ដោស ១ ឆ្នាំទៀត ។ ធ្វើកតិកាយ៉ាងនេះ យើងទើបអាចនឹងចៀសវាងពីសឹកសង្គ្រាមបានដោយឧបាយប៉ុណ្ណោះ» ។

ព្រះរាជាទ្រង់ជាអ្នកមានព្រះទ័យទន់ ក៏យល់ព្រមបណ្ដោយតាមព្រះរាជឱរស ត្រាស់ប្រើព្រះរាជអាមាត្យឲ្យតាមទៅហៅបាណ្ឌពក្សត្រិយ៍ទាំងនោះត្រឡប់មកវិញ ទើបបានលេងស្កាភ្នាល់ម្ដងទៀត ។

យុធិស្ឋិរ និងសកុនិ អង្គុយទល់មុខគ្នាចាប់លេងទៅតាមតម្រិះប្រាជ្ញា ហើយប្រុងជើងការយកប្រៀបតែសព្វខ្លួន ។ សកុនិយកកូនស្កាបង្កប់សំណាមកលេងទៀត យុធិស្ឋិរក៏ចាញ់ដូចពីលើកមុន ក្នុងទីបំផុតព្រះអង្គ និងអនុភាតា ព្រះនាង ទ្រៅបទីទេវី ត្រូវទទួលការបរាជ័យដ៏ជាផលនៃល្បែងភ្នាល់ស្កា ត្រូវគេនិរទេសចេញចាកនិវេសន៍មហាស្ថាន ។